ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃ ចន្ទ ១០ រោច ខែ អស្សុជ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពី "ក្របខណ្ឌតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម កម្ពុជា ២០១៥-២០២៥ (IDP)"

នាព្រឹកថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាលើ "**ក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ (Industrial Development Policy - IDP)**" និងការរៀបចំនូវ "**សូចនាករគន្លឹះកម្រិតយុទ្ធសាស្ត្រ និងកម្រិតវិស័យ**" សម្រាប់ការអនុវត្ត គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជានេះ ។ កិច្ចប្រជុំ មានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តមទេសរដ្ឋមន្ត្រី, ឯកឧត្តមរដ្ឋមន្ត្រី និងឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់ រាជរដ្ឋាភិបាល ។

រៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្របខណ្ឌតាមដាន និងវាយតម្លៃ ការអនុវត្ត IDP នេះ មានគោលបំណង÷ ១. រៀបចំឱ្យមានប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្ត IDP ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ, ២. កំណត់អំពីដំណើរការ, វិធីសាស្ត្រ, យន្តការ និងស្ថាប័នទទួលខុសត្រូវក្នុងការរាយការណ៍, គ្រប់គ្រង និងវិភាគទិន្នន័យ និងការរៀបចំរបាយការណ៍តាមដាន និងវាយតម្លៃ និង ៣. កំណត់ពីបញ្ហាប្រឈម និងហានិភ័យ ក្នុងការតាមដាន និងវាយតម្លៃ ។ ក្នុងន័យនេះ, ការតាមដាន និងវាយតម្លៃការអនុវត្ត IDP បានចែកចេញជា ៣ កម្រិត គឺ÷

- **កម្រិតយុទ្ធសាស្ត្រ ឬកម្រិតម៉ាក្រូ** ផ្តោតលើចក្ខុវិស័យ រួមទាំងគោលបំណង និងគោលដៅ ជាលទ្ធផលចុងក្រោយ ឬរយៈពេលវែង (Final Outcome) ដែលជាបច្ច័យចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម,
- **កម្រិតវិស័យ** ផ្តោតលើក្របខណ្ឌយុទ្ធសាស្ត្រ ជាលទ្ធផលបន្ទាប់ ឬ រយៈពេលមធ្យម (Immediate Outcome) នៃគោលនយោបាយ, និង

- **កម្រិតប្រតិបត្តិ** ផ្តោតលើវិធានការគន្លឹះបួនជាក់ស្តែង និងវិធានការគោលនយោបាយ និងផែនការសកម្មភាព ជាលទ្ធផលដំបូង ឬ រយៈពេលខ្លី (Outputs)។

ជារួម, អង្គប្រជុំ បានឯកភាពថា ក្របខណ្ឌតាមដាន និងវាយតម្លៃនេះ នឹងដើរតួជាត្រីវិស័យក្នុងការរៀបចំ និងអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្ត IDP ដ៏ពេញលេញមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ, មានតម្លាភាព និងមានការចូលរួមពិគ្រោះយោបល់ពីគ្រប់តួអង្គពាក់ព័ន្ធ ដោយមានកំណត់នូវសូចនាករ និងគោលដៅថ្មីបន្ថែមទៀត ដែលអាចវាស់វែងបាន ហើយឆ្លើយតបទៅនឹងអាទិភាពនៃតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ។ ទោះបីជាយ៉ាងនេះក្តី, សូចនាករសរុបមានចំនួនច្រើន ដែលទាមទារការពិនិត្យឡើងវិញផ្អែកលើទិដ្ឋភាពទិន្នន័យ និងភាពប្រទាក់ក្រឡាគ្នាជាមួយនឹងគោលបំណងគោលនយោបាយដែលបានកំណត់ក្នុង IDP ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំ បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានខិតខំប្រឹងប្រែង និងចូលរួមយ៉ាងសកម្មក្នុងការរៀបចំ និងផ្តល់ធាតុចូលដ៏មានសារៈសំខាន់ ក្នុងការរៀបចំក្របខណ្ឌតាមដាន និងវាយតម្លៃនេះ ព្រមទាំងលើកទឹកចិត្តដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ បន្តខិតខំអនុវត្ត និងផ្តល់កិច្ចសហប្រតិបត្តិការប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ តាមមុខសញ្ញា និងភាពពាក់ព័ន្ធរៀងៗខ្លួន ។